វាយឡើងវិញជាភាសាខ្មែរពីឯកសារផ្លូវការ

ក្រុមប្រឹក្សារដ្ឋមន្ត្រី

*លេខ ២៥ អនក្រ./ថ្ងៃទី ២២ ខែ មេសា ១៩៨៩*

អនុក្រឹត្យស្តីពីការផ្តល់កម្មសិទ្ធិលើផ្ទះជូនពលរដ្ឋកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា
- បានឃើញច្បាប់ស្តីពីអង្គការចាត់តាំង និង សកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយក្រឹត្យលេខ ០៣ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២
- បានឃើញក្រឹត្យច្បាប់លេខ ០៧ ក្រ.ច ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ១៩៨២ ស្តីពីសមត្ថកិច្ច និង នីតិវិធីនៃការធ្វើច្បាប់ និង បទបញ្ញា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ១៩៨១ ស្តីពីរបៀបរៀបរយសាធារណៈក្នុងរដ្ឋធានី
- បានឃើញអនុក្រឹត្យលេខ ០៣ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៨២ ស្តីពីតម្លៃឈ្នួលផ្ទះក្នុងទីក្រុងភ្នំពេញ

សំរេច

មាត្រា ១

ដីសង់លំនៅដ្ឋាន និង អគារធំ តូច ផ្ទះជាភូមិគ្រឹះ ផ្ទះដាច់ដោយឡែកឯទៀត ឬ ផ្ទះល្វែងទាំងអស់ក្នុងទូទាំងសាធារណរដ្ឋប្រជាមានិតកម្ពុជា ជាទ្រព្យសម្បត្តិរួមរបស់ប្រជាជនដែលរដ្ឋគ្រប់គ្រងតាមច្បាប់ជាធរមាន ។

គ្មានជនណាមួយអាចទាមទារសិទ្ធិលើកម្មសិទ្ធិចាស់មុនឆ្នាំ ១៩៧៩ លើដីសង់លំនៅដ្ឋាន ឬ លើផ្ទះប្រភេទណាមួយបានឡើយ ។

មាត្រា ២

ចាប់ពីថ្ងៃនេះតទៅ រដ្ឋបែងចែកកម្មសិទ្ធិដាច់អោយគ្រួសារជាពលរដ្ឋកម្ពុជា លើលំនៅដ្ឋានដែលគ្រួសាររបស់ខ្លួនកំពុងរស់នៅក្នុងឃុំ សង្កាត់ទូទាំងប្រទេស ហើយដែលរដ្ឋអំណាចឃុំ សង្កាត់នោះទទួលស្គាល់ ។ គ្រួសារពលរដ្ឋកម្ពុជាដែលរស់នៅលើលំនៅដ្ឋានណាដែលជាផ្ទះភូមិគ្រឹះ ផ្ទះដាច់ដោយឡែកឯទៀត ឬ ផ្ទះល្វែង ត្រូវបានទទួលកម្មសិទ្ធិកាន់កាប់ ប្រើប្រាស់លំនៅដ្ឋាននោះ ដែលសន្មតហៅថា ផ្ទះសំរាប់រស់នៅតរៀងទៅ ។

កម្មសិទ្ធិលើផ្ទះនេះ អាចបន្តមរតកទៅកូន-ចៅកាន់កាប់ ប្រើប្រាស់ដោយគ្មានកំណត់ពេល ឬ ប្រគល់ជាអំណោយអោយទៅបងប្អូនញាតិមិត្ត ឬ លក់អោយទៅអ្នកដទៃណាមួយទៀតកាន់កាប់ ប្រើប្រាស់បាន លើកលែងតែការប្រើប្រាស់ដោយអ្នកទាំងនោះ បំរើគោលដៅ និង ផលប្រយោជន៍ដែលផ្ទុយនឹងច្បាប់កំណត់ ។ រដ្ឋហាមឃាត់ការលក់ផ្ទះ និង ដីសង់លំនៅដ្ឋានទៅអោយជនបរទេស ។

មាត្រា ៣

ម្ចាស់លំនៅដ្ឋានដូចបានកំណត់ខាងលើនេះ ត្រូវបង់ថ្លៃឈ្នួលដីប្រចាំឆ្នាំលើដីឡូតិ៍ ដែលលំនៅដ្ឋាននោះស្ថិតនៅលើ ។

បើលំនៅដ្ឋាននោះជាផ្ទះល្វែងក្នុងអគាររួមមួយ ឬ ជាភាគមួយនៃផ្ទះទាំងមូល ម្ចាស់ផ្ទះល្វែង ឬ ម្ចាស់ភាគនីមួយ ៗ ត្រូវរួមវិភាគទានបង់ថ្លៃឈ្នួលដីដែលអគាររួម ឬ ផ្ទះទាំងមូលស្ថិតនៅលើ តាមសមាមាត្រនៃផ្ទៃក្រឡាសំណង់ដែលកាន់កាប់រៀង ៗ ខ្លួន ។

ប្រាក់ឈ្នួលដីប្រចាំឆ្នាំនេះ មិនអាចអោយលើសពី ប្រាំ ភាគរយនៃប្រាក់បំណាច់សុទ្ធរបស់កម្មាភិបាល បុគ្គលិក កម្មករ និង កងកំលាំងប្រដាប់អាវុធ ។

មាត្រា ៤ :

មេក្រុមគ្រួសារដែលកំពុងរស់នៅលំនៅដ្ឋាន ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ ឃុំ សង្កាត់ ណាត្រូវធ្វើលិខិតសុំកាន់កាប់កម្មសិទ្ធិលើលំនៅដ្ឋាន ដែលខ្លួនរស់នៅ តាមរយៈរដ្ឋអំណាចឃុំ សង្កាត់នោះ ។

កម្មាភិបាល បុគ្គលិក កម្មករ កងកម្លាំងប្រដាប់អាវុធ ត្រូវធ្វើលិខិតសុំតាមរយៈក្រសួង មន្ទីរ ឬ អង្គភាពរបស់ខ្លួន ដែលត្រូវបញ្ជូនលិខិតនោះ ទៅគណៈកម្មាធិការប្រជាជន បដិវត្តខេត្ត-ក្រុងចាត់ការតាមសមត្ថកិច្ច ។

គណៈកម្មាធិការប្រជាជន បដិវត្តខេត្ត-ក្រុង ជាអង្គការមានសមត្ថកិច្ចចេញវិញ្ញាបនប័ត្រជូនពលរដ្ឋសំរាប់ប្រើប្រាស់ជាផ្លូវការ ។

មាត្រា ៥:

ក្រៅពីកម្មាភិបាល បុគ្គលិក កម្មករ កងកម្លាំងប្រដាប់អាវុធ ប្រជាជនដែលកំពុងរស់នៅលំនៅដ្ឋាន ឬ ដីសង់លំនៅដ្ឋានណាមួយ ត្រូវសុំទិញលំនៅដ្ឋាន ឬ ដីសង់លំនៅដ្ឋាននោះផ្ដាច់ពីរដ្ឋទុកជាកម្មសិទ្ធិផ្ទាស់របស់ខ្លួន លើកលែងតែប្រជាជន ដែលបានចេញថវិកាសង់លំនៅដ្ឋាននោះ ដោយខ្លួនឯង ។

លំនៅដ្ឋានសង់ដោយខ្លួនឯង ត្រូវទុកជាកម្មសិទ្ធិផ្ទាស់របស់សាម៉ីជន ដែលបានសាងសង់ ។ ក្នុងករណីពិសេសគណៈកម្មាធិការប្រជាជនបដិវត្ត ខេត្ត -ក្រុង ត្រូវកំណត់គោលនយោបាយជាក់ស្តែង ។ ថ្លៃលំនៅដ្ឋាន ត្រូវកំណត់តាមផ្ទៃក្រឡាកាន់កាប់តាមប្រភេទ និងស្ថានភាពផ្ទះ និងតាមគោលដៅប្រើប្រាស់ ។ ក្រុមប្រឹក្សារដ្ឋមន្ត្រីប្រគល់ជូនគណៈកម្មាធិការប្រជាជនបដិវត្តខេត្ត-ក្រុងកំណត់ថ្លៃខាងលើនេះតាមសភាពការណ៍ជាក់ស្តែង នៃខេត្ត -ក្រុងនីមួយៗ ។

មាត្រា ៦ :

ក្រុមគ្រួសារណា ឬ ជនទាំងឡាយណាដែលកំពុងរស់នៅ ឬ ក្របកអាជីវកម្មក្នុងអាគារសាធារណៈគ្មានសិទ្ធិទទួលកម្មសិទ្ធិលើផ្នែកណាមួយ បលើអាគារសាធារណៈនោះឡើយ ។

អាគារសាធារណៈទាំងឡាយ ត្រូវប្រគល់ជូនរដ្ឋមន្ត្រីប្រើប្រាស់ជាចាំបាច់សំថរាប់ផលប្រយោជន៏សាធារណៈ ។

មាត្រា ៧:

ការលក់ដូរផ្ទះ ឬ ការធ្វើអំណោយផ្ទះ ត្រូវធ្វើដោយកិច្ចសន្យាដែលអ្នកទិញ ឬ អ្នកទទួលអំណោយត្រូវយកទៅចុះបញ្ជីប្រថាប់ត្រា ហើយបង់ថ្លៃប្រថាប់ត្រាចំនួនដប់ភាគរយ នៃតម្លៃផ្ទះតាម ប្រភេទផ្ទះ សំរាប់នៅសំរាប់ធ្វើអាជីវកម្ម សេវាកម្ម សិប្បកម្ម សិប្បកម្ម ឬ ឧស្សាហកម្ម ។

មាត្រា ៨:

ផ្ទះដែលយកទៅបំរើទិសដៅធ្វើអាជីវកម្ម សេវាកម្ម សិប្បកម្ម សិប្បកម្ម ឬ ឧស្សាហកម្ម ត្រូវបង់ពន្ធជូនរដ្ឋ ។ អាត្រាពន្ធនេះត្រូវកំណត់ដោយក្រុមប្រឹក្សារដ្ឋមន្ត្រី តាមផ្ទៃក្រឡាបំរើអាជីវកម្ម-ផលិតកម្ម ។

មាត្រា ៩:

ម្ចាស់ផ្ទះទាំងឡាយមានកាតព្វកិច្ចថែទាំ សំអាត ជួសជុលផ្ទះអោយបានល្អ គង់វងជានិច្ច ហើយត្រូវរក្សាអនាម័យខ្ពស់ មិនត្រូវអោយលិចឡើងនូវក្លិន ឬ សូរសម្លេងដែលប៉ះពាល់ដល់សុខុមាលភាព និងភាពស្ងប់ស្ងៀមនៅជុំវិញខ្លួនឡើយ ។

មាត្រា ១០:

សំណង់បន្ថែម ឬ សំណង់ថ្មី ត្រូវមានការអនុញ្ញាតពីគណៈកម្មាធិការប្រជាជនបដិវត្តខេត្ត-ក្រុងជាមុនសិន ។

វាយឡើងវិញជាភាសាខ្មែរពីឯកសារផ្លូវការ

មាត្រា ១១ :

គណៈកម្មាធិការប្រជាជនបដិវត្តខេត្ត-ក្រុង ត្រូវទទួលខុសត្រូវចំពោះការគ្រប់គ្រងផ្ទះ សំណង់គ្រប់ប្រភេទ និងការត្រួតពិនិត្យការចុះបញ្ជីការបែងចែកកម្មសិទ្ធិលើផ្ទះ ការប្រើប្រាស់ផ្ទះ ការប្រើប្រាស់ផ្ទះ ការទារឈ្នួលដី ទារពន្ធ និងទទួលខុសត្រូវចំពោះការថែទាំផ្លូវសាធារណៈ ធំ តូចលូវបង្ហូរទឹកអនាម័យនៅទីសាធារណៈ និងភាពស្ងប់ស្ងៀមនៅក្នុងរង្វង់ភូមិសាស្ត្រនៃការគ្រប់គ្រងរបស់ខ្លួន ។

មាត្រា ១២:

បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជាមោឃៈ ។

មាត្រា ១៣:

ខុទ្ទការល័យប្រឹក្សារដ្ឋមន្ត្រី គ្រប់ក្រសួង មន្ទីរ និងគណៈកម្មាធិការប្រជាជនបដិវត្តខេត្ត-ក្រុង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ។

មាត្រា ១៤ :

អនុក្រឹត្យនេះមានអនុភាពគតិយុត្តិ ចាប់តាំងពីថ្ងៃប្រកាសផ្សាយជាសាធារណៈ ។